ធ៥-០១-២០១ ប្រ.ក

# ប្រកាស
# ស្តីពី
# ការកំណត់អត្រាការប្រាក់ជាគោលសម្រាប់បុនហិរញ្ញប្បទាន

**ប្រការ ១**.-

កំណត់អត្រាការប្រាក់ជាគោល ០,៥០% ក្នុងមួយខែ ឬ ៦%ក្នុងមួយឆ្នាំ សម្រាប់អនុវត្តចំពោះការផ្តល់បុនហិរញ្ញប្បទាន ជាប្រាក់រៀលដល់ធនាគារពាណិជ្ជ ដើម្បីឱ្យធនាគារពាណិជ្ជទាំងឡាយអនុវត្តបានល្អនូវការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់របស់ខ្លួន។

**ប្រការ ២**.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តនូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៤**.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០២ នេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០១

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**